**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៦៥ សហវ.ប្រក.

# ប្រកាសអន្តរក្រសួង
## ស្តីពី
## លក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុសម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុ មានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡានៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០១៧ ស្តីពីការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៨២ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- បានឃើញអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ២១៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ
- បានឃើញប្រកាសអន្តរក្រសួងលេខ ៥០៨ សហវ.ប្រក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៣ ស្តីពីគោលការណ៍ចំណាយសម្រាប់អនុវត្តថវិកាកម្មវិធីនៅក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ មានគោលដៅកំណត់លក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុ សម្រាប់ការផ្ទេរការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីចូលរួមចំណែកជានាប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព និងគណនេយ្យភាព នៃការអនុវត្តមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡា ដែលបានប្រគល់ និងបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**ប្រការ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តនៅគ្រប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងក្របខ័ណ្ឌនៃការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ ដោយមានការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាសេនាធិការ ដើម្បីគាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡា ដែលបានប្រគល់ និងបានធ្វើប្រតិភូកម្ម និងមានគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ជាអង្គភាពអនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ដែលបានប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

## ជំពូកទី២
## សិទ្ធិអំណាច ការទទួលខុសត្រូវ និងគណនេយ្យភាព ក្នុងការគ្រប់គ្រងថវិកា

**ប្រការ៣.-**

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវមានការទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និងស្ថាប័ននីតិប្បញ្ញត្តិលើវិស័យអប់រំ។

ក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវមានការទទួលខុសត្រូវ និងមានគណនេយ្យភាពខាងលទ្ធផលចំពោះរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា តាមរយៈមន្ទីរអប់រំ យុវជន និងកីឡា ក្នុងការអនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ដែលបានប្រគល់ និងការគាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡា ដែលបានប្រគល់ និងបានធ្វើប្រតិភូកម្មមកឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឱ្យឆ្លើយតបទៅនឹងគោលនយោបាយអាទិភាពវិស័យអប់រំ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ កម្មវិធីកែទម្រង់វិស័យអប់រំ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ព្រមទាំងត្រូវមានគណនេយ្យភាពចំពោះប្រជាជនក្នុងការផ្តល់សេវាអប់រំក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ទំព័រទីព

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានការិយាល័យអប់រំ យុវជន និងកីឡា ជាសេនាធិការ ត្រូវចូលរួមគាំទ្រ និងសហការជាមួយមន្ទីរអប់រំ យុវជន និងកីឡា លើការអនុវត្តមុខងារគ្រប់គ្រងការអប់រំកម្រិតមធ្យមសិក្សា ការងារយុវជន ការងារកីឡា និងការងារផ្សេងទៀត ដែលពុំទាន់បានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ប្រធានការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបំពេញតួនាទីជាសេនាធិការ ឱ្យក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងមានការទទួលខុសត្រូវ និងមានគណនេយ្យភាពខាងលទ្ធផល ចំពោះក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ខណ្ឌ លើការអនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ ដែលបានប្រគល់ និងការគាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡា នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលបានប្រគល់ និងបានធ្វើប្រតិភូកម្ម។

ប្រធានការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលជាប្រតិបត្តិករផ្ទាល់លើការគាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡានៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលត្រូវបានប្រគល់ និងបានធ្វើប្រតិភូកម្ម ត្រូវមានការទទួលខុសត្រូវ និងមានគណនេយ្យភាពខាងលទ្ធផល ចំពោះអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងត្រូវមានការទទួលខុសត្រូវ និងមានគណនេយ្យភាពក្នុងការគ្រប់គ្រងសាច់ប្រាក់ និងការចំណាយ ព្រមទាំងនីតិវិធីហិរញ្ញវត្ថុពាក់ព័ន្ធជាធរមាន ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងតម្លាភាព។

នាយក ឬ ប្រធានគណៈគ្រប់គ្រងគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ដែលជាប្រតិបត្តិករផ្ទាល់ ត្រូវមានការទទួលខុសត្រូវ និងមានគណនេយ្យភាពខាងលទ្ធផល ចំពោះប្រធានការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងត្រូវមានការទទួលខុសត្រូវ និងមានគណនេយ្យភាព ក្នុងការគ្រប់គ្រងសាច់ប្រាក់ និងការចំណាយ ព្រមទាំងនីតិវិធីហិរញ្ញវត្ថុពាក់ព័ន្ធជាធរមាន ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងតម្លាភាព។

**ប្រការ៤._**

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការិយាល័យអប់រំ យុវជន និងកីឡា ជាសេនាធិការ ត្រូវរៀបចំផែនការសកម្មភាពប្រចាំឆ្នាំសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ដែលត្រូវបានប្រគល់ និងការគាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងការអនុវត្តមុខងារអប់រំ យុវជន និងកីឡានៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលបានប្រគល់ និងបានធ្វើប្រតិភូកម្ម។

នៅក្នុងដំណាក់កាលនៃការរៀបចំថវិកា ដោយផ្អែកលើផែនការសកម្មភាពប្រចាំឆ្នាំ និងក្នុងក្របខ័ណ្ឌនៃការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដោយមានកិច្ចសហការពីមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងក្រសួងអប់រំ យុវជន និងកីឡា ត្រូវដឹកនាំ និងណែនាំការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឱ្យរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ស្របតាមលក្ខខណ្ឌនានា និងតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន និងស្របតាមសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាថ្នាក់ជាតិ និងសារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ដើម្បីដាក់ជូនអភិបាលនៃគណៈអភិបាល និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ពិនិត្យ និងអនុម័ត រួចបញ្ជូនទៅក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈមន្ទីរអប់រំ យុវជន និងកីឡា។

នៅក្នុងដំណាក់កាលនៃការអនុវត្តថវិកា អភិបាលនៃគណៈអភិបាលក្រុង ស្រុក គឺជាអាណាប័កដើមខ្សែនៃថវិកា ក្នុងការបញ្ជាប្រតិបត្តិការចំណូល និងធ្វើប្រតិបត្តិការចំណាយថវិកាក្នុងវង្វង់ឥណទានថវិការបស់រដ្ឋបាលក្រុង ស្រុកសាមី។ ដោយឡែក អភិបាលនៃគណៈអភិបាលរាជធានី គឺជាអាណាប័កដើមខ្សែនៃថវិកា ត្រូវចេញសេចក្តីសម្រេចតែងតាំងអភិបាលនៃគណៈអភិបាលខណ្ឌ ជាអាណាប័កផ្ទេរសិទ្ធិនៃថវិកា ក្នុងការបញ្ជាប្រតិបត្តិការចំណូល និងធ្វើប្រតិបត្តិការចំណាយថវិកាក្នុងវង្វង់ឥណទានថវិការបស់រដ្ឋបាលខណ្ឌសាមី។ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានការិយាល័យអប់រំ យុវជន និងកីឡា ជាសេនាធិការ ត្រូវរៀបចំ និងអនុវត្តថវិកាឱ្យស្របតាមគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ នីតិវិធីនៃការអនុវត្តថវិកាដំណើរការការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងនីតិវិធីស្តីពីការរៀបចំ និងការអនុវត្តថវិកាសមិទ្ធកម្ម។ ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ដែលទទួលសាច់ប្រាក់ពីរតនាគាររាជធានី ខេត្ត តាមរយៈគណនីធនាគាររបស់ខ្លួន ត្រូវអនុវត្តចំណាយស្របតាមគោលការណ៍ហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងតម្លាភាព។ មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ដែលទទួលសាច់ប្រាក់ពីការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តចំណាយស្របតាមគោលការណ៍ហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងតម្លាភាព។

## ជំពូកទី៣
## ការរៀបចំគម្រោងថវិកា

**ប្រការ៥.**_

កញ្ចប់ថវិកា រួមទាំងចំណាយបន្ទុកបុគ្គលិក សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ព្រមទាំងកញ្ចប់ថវិកា រួមទាំងចំណាយបន្ទុកបុគ្គលិក របស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងការគាំទ្រការអនុវត្តមុខងារដែលបានប្រគល់ និងបានធ្វើប្រតិភូកម្ម ត្រូវបានគ្រោងជាឧបសម្ព័ន្ធនៃកញ្ចប់ថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់ពិភាក្សាភ្ជាប់គ្នាជាមួយនឹងគម្រោងថវិការបស់មន្ទីរអប់រំ យុវជន និងកីឡា និងរដ្ឋបាលកណ្តាលនៃក្រសួងអប់រំ យុវជន និងកីឡា ក្នុងក្របខ័ណ្ឌនៃថវិកាវិស័យអប់រំ ព្រមទាំងក្នុងក្របខ័ណ្ឌនៃការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌដើម្បីចូលរួមចំណែកសម្រេចគោលបំណងគោលនយោបាយជាក់លាក់នៃវិស័យអប់រំ។

ដើម្បីធានាដល់ការរៀបចំគម្រោងថវិកាប្រចាំឆ្នាំឱ្យបានគ្រប់ជ្រុងជ្រោយ និងមានប្រសិទ្ធភាព នៅក្នុងត្រីមាសទី១ នៃឆ្នាំនីមួយៗ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវលើកសំណើជូនក្រសួងអប់រំ យុវជន និងកីឡា តាមរយៈមន្ទីរអប់រំ យុវជន និងកីឡា អំពីតម្រូវការគ្រូបង្រៀន និងបុគ្គលិកអប់រំ ព្រមទាំងតម្រូវការនៃការបណ្តុះបណ្តាលគ្រូ និងបុគ្គលិកអប់រំដែលកំពុងបម្រើការនៅតាមសាលារៀន មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ និងនៅតាមការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ស្របតាមផែនការអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យអប់រំ ការជ្រើសរើស និងការបែងចែកគ្រូ និងបុគ្គលិកអប់រំ រួមទាំងការផ្តល់ការបណ្តុះបណ្តាលមូលដ្ឋាន និងការបណ្តុះបណ្តាលបន្ត។

កញ្ចប់ថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ត្រូវគ្រោងផ្អែកតាមបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ចំពោះកញ្ចប់ថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ ត្រូវគ្រោងទៅតាមគោលការណ៍ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

កញ្ចប់ថវិការបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ រួមទាំងចំណាយបន្ទុកបុគ្គលិក ក្នុងការគាំទ្រការអនុវត្តមុខងារដែលបានប្រគល់ និងបានធ្វើប្រតិភូកម្ម ត្រូវគ្រោងផ្អែកតាមតម្រូវការចំណាយជាក់ស្តែង និងក្នុងកម្រិតពិតានចំណាយដែលបានកំណត់។ ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវគ្រោងចំណាយមិនមែនបន្ទុកបុគ្គលិក ក្នុងអនុគណនី ៦២០២៨ (ជំនួយសង្គមផ្សេងៗទៀត)។

**ប្រការ៦._**

ដំណើរការនៃការរៀបចំថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ និងថវិកាសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងថវិការបស់មន្ទីរអប់រំ យុវជន និងកីឡា និងរដ្ឋបាលកណ្តាលនៃក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំរួមគ្នា ស្របតាមប្រតិទិននៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីធានាសង្គតិភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយវិស័យអប់រំ។

ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវមមួលបន្ទុកសម្របសម្រួល បូកសរុប និងរៀបចំគម្រោងថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងក្របខ័ណ្ឌនៃថវិកាវិស័យអប់រំ ក្រោមការដឹកនាំ និងការណែនាំរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងដោយមានការគាំទ្របច្ចេកទេសពីមន្ទីរអប់រំ យុវជន និងកីឡា និងក្រសួងអប់រំ យុវជន និងកីឡា រួចបញ្ជូនទៅសុំការពិនិត្យ និងឯកភាពពីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ មុននឹងដាក់ជូនក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ពិនិត្យ និងអនុម័ត។ បន្ទាប់ពីទទួលបានការអនុម័តពីក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណើគម្រោងថវិកានេះ តាមរយៈមន្ទីរអប់រំ យុវជន និងកីឡា ជូនក្រសួងអប់រំ យុវជន និងកីឡា១ (មួយ) ច្បាប់ ដើម្បីពិនិត្យសង្គតិភាពឱ្យស្របតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំ បែបបទនៃការរៀបចំផែនការសកម្មភាពអប់រំ យុវជន និងកីឡា និងរចនាសម្ព័ន្ធកម្មវិធីដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា និង១ (មួយ) ច្បាប់ទៀត ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យការផ្សារភ្ជាប់គម្រោងថវិកានេះ ជាមួយគម្រោងថវិការបស់ក្រសួងអប់រំ យុវជន និងកីឡាទាំងមូល។

សំណើគម្រោងថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ នឹងត្រូវដាក់ពិភាក្សាការពាររួមគ្នាជាមួយនឹងសំណើគម្រោងថវិការបស់មន្ទីរអប់រំ យុវជន និងកីឡា និងថវិការដ្ឋបាលកណ្តាលនៃក្រសួងអប់រំ យុវជន និងកីឡា។ កិច្ចពិភាក្សាការពារគម្រោងថវិកានេះ នឹងប្រព្រឹត្តទៅជា ២ (ពីរ) កម្រិត រួមមាន កម្រិតបច្ចេកទេស ដែលត្រូវរៀបចំ និងដឹកនាំដោយថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានថវិកា និងកម្រិតថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ដែលត្រូវដឹកនាំដោយថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ដើម្បីពិនិត្យផ្តល់កញ្ចប់ថវិកាទៅតាមលទ្ធភាពថវិកាជាតិប្រចាំឆ្នាំក្នុងក្របខ័ណ្ឌនៃថវិកាវិស័យអប់រំ ព្រមទាំងក្នុងក្របខ័ណ្ឌនៃការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ ដើម្បីចូលរួមចំណែកសម្រេចគោលបំណងគោលនយោបាយជាក់លាក់នៃវិស័យអប់រំ។

គម្រោងថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ នឹងត្រូវផ្តល់ជូនផ្អែកតាមគោលការណ៍ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ក្នុងករណីមានការសម្រេចដោយឡែកពាក់ព័ន្ធនឹងការកាត់បន្ថយ ឬបង្កើនទំហំថវិកា ទៅតាមលទ្ធភាព និងភាពទ្រទ្រង់បាននៃថវិកាប្រចាំឆ្នាំ លើសំណើគម្រោងថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរតាមការចាំបាច់ដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**ប្រការ៧._**

ឥណទានថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលត្រូវបានអនុម័តដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ គឺជាឧបសម្ព័ន្ធនៃកញ្ចប់ថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ នឹងត្រូវបានរៀបចំលម្អិតជាសៀវភៅថវិកា តាមការកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ជូនទៅអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដើម្បីអនុវត្ត និងសម្រាប់ជូនទៅមន្ទីរអប់រំ យុវជន និងកីឡា ព្រមទាំងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីតាមដានការអនុវត្តក្នុងក្របខ័ណ្ឌវិស័យអប់រំ។

បន្ថែមពីលើធនធានហិរញ្ញវត្ថុប្រចាំឆ្នាំសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលទទួលបានពីថវិកាថ្នាក់ជាតិតាមលទ្ធភាពថវិកាប្រចាំឆ្នាំ ក្នុងក្របខ័ណ្ឌនៃកញ្ចប់ថវិកាវិស័យអប់រំ រដ្ឋបាលក្រុង ស្រុក ខណ្ឌ អាចប្រើប្រាស់ចំណែកធនធានហិរញ្ញវត្ថុគ្មានភ្ជាប់លក្ខខណ្ឌ ចំណែកធនធានដែលទទួលបានពីថវិការាជធានី និងធនធានដែលគៀរគរបានពីប្រភពស្របច្បាប់ផ្សេងទៀត សម្រាប់គាំទ្រដល់ការអនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ឥណទានថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលត្រូវបានបែងចែកលម្អិតទៅតាមចំណាត់ថ្នាក់នៃមាតិកាថវិកា ដូចមានចែងក្នុងសៀវភៅថវិកាដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានផ្ទេរជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីអនុវត្តឱ្យបានទាន់ពេលវេលាចាប់ពីថ្ងៃទី១ ខែមករា នៃឆ្នាំថវិកា។

# ជំពូកទី៤
# នីតិវិធីនៃការអនុវត្តថវិកា
## ផ្នែកទី១
## ការបើកសាច់ប្រាក់

**ប្រការ៨._**

ថវិកាចំណាយមិនមែនបន្ទុកបុគ្គលិក សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការបើកផ្តល់សាច់ប្រាក់មុន។

ការបើកផ្តល់សាច់ប្រាក់មុន គឺជានីតិវិធីដែលតម្រូវឱ្យផ្តល់សាច់ប្រាក់ជាមុនចំនួន១០០% (មួយរយភាគរយ) ដែលត្រូវបើកផ្តល់ចំនួន២ (ពីរ) លើក ក្នុង១ ឆ្នាំ គឺលើកទី១ នៅដើមខែមករា និងលើកទី២ នៅដើមខែមិថុនា នៃឆ្នាំនីមួយៗ។ កម្មវិធីចំណាយប្រចាំត្រីមាស ត្រូវរៀបចំឡើងដោយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ បន្ទាប់មកបញ្ជូនទៅការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៃរដ្ឋបាលក្រុង ស្រុក និងការិយាល័យផែនការ និងហិរញ្ញវត្ថុនៃរដ្ឋបាលខណ្ឌ ពិនិត្យ និងដាក់ជូនគណៈអភិបាលក្រុង ស្រុក ខណ្ឌ ពិនិត្យនិងសម្រេច និងបញ្ជូនទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត តាមរយៈមន្ទីរអប់រំ យុវជន និងកីឡា ដើម្បីបូកសរុប និងផ្ញើមកអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ កម្មវិធីចំណាយប្រចាំត្រីមាស ត្រូវបានប្រើប្រាស់សម្រាប់ការទូទាត់ចំណាយតាមត្រីមាសនីមួយៗ។

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់តាំងបុគ្គលិកការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ ១ (មួយ) រូប ជាមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីកាន់កាប់សាច់ប្រាក់ដែលបានបើកផ្តល់ឱ្យមុន សម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសម្រាប់អនុវត្តមុខងារអប់រំក្រៅប្រព័ន្ធ។ មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវមានតួនាទី ភារកិច្ច និងការទទួលខុសត្រូវ ដូចខាងក្រោម៖

- ចូលរួមក្នុងដំណើរការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- រៀបចំមូលប្បទានប័ត្រដក ឬបញ្ជាផ្ទេរប្រាក់ពីធនាគារដើម្បីដាក់ជូនប្រធានការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ពិនិត្យ និងសម្រេច
- ដកសាច់ប្រាក់ពីគណនីនៅធនាគារ និងរក្សាសាច់ប្រាក់ទុកក្នុងបេឡា
- កាន់បញ្ជីតាមដានប្រាក់ក្នុងធនាគារ និងបញ្ជីបេឡា
- រៀបចំបណ្ណចំណូល និងបណ្ណចំណាយ ដាក់ជូនប្រធានការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌពិនិត្យ និងសម្រេចតាមឋានានុក្រម
- បើកសាច់ប្រាក់ ឬផ្ទេរប្រាក់ជូនអ្នកស្នើសុំ ផ្អែកតាមសំណើចំណាយថវិកា
- រៀបចំរបាយការណ៍ចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងសកម្មភាព និងរបាយការណ៍ទូទាត់ចំណាយថវិកាសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសម្រាប់អនុវត្តមុខងារអប់រំក្រៅប្រព័ន្ធ

- រៀបចំទុកដាក់ឯកសារ ឬសក្ខីបត្រចំណាយលើការគាំទ្រផ្សេងៗពាក់ព័ន្ធនឹងការចំណាយថវិកាសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសម្រាប់អនុវត្តមុខងារអប់រំក្រៅប្រព័ន្ធ ឱ្យបានត្រឹមត្រូវ និងមានសុវត្ថិភាពសម្រាប់ជាកម្មវត្ថុនៃការតាមដាន អធិការកិច្ច និងសវនកម្ម
- ទទួលខុសត្រូវជាលក្ខណៈបុគ្គល និងប្រាក់កាស ដោយមិនទាន់គិតដល់ទណ្ឌកម្មរដ្ឋបាល ទណ្ឌកម្មព្រហ្មទណ្ឌ និងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងទៀត ចំពោះការថែរក្សាការពារមូលនិធិដែលខ្លួនទទួលបាន ឬបានចំណាយ ការរក្សាទុកដាក់លិខិតយុត្តិការ និងការកត់ត្រាបញ្ជីគណនេយ្យ។

បន្ថែមពីនេះ មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុនៃការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក៏ត្រូវមានតួនាទី ភារកិច្ច និងការទទួលខុសត្រូវ ដូចខាងក្រោម៖

- ចូលរួមរៀបចំ និងបូកសរុបផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ
- ចូលរួមរៀបចំ និងបូកសរុបកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ
- ប្រមូល និងរៀបចំរបាយការណ៍បូកសរុបទូទាត់ចំណាយថវិការបស់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ
- ផ្ដល់ការគាំទ្រ និងសហការក្នុងដំណើរការពិនិត្យតាមដាន អធិការកិច្ច និងសវនកម្មលើការចំណាយថវិការបស់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**ប្រការ៩.**_

ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំសំណើសុំបើកសាច់ប្រាក់មុនតាមពេលកំណត់ដូចមានចែងក្នុងប្រការ៨ នៃប្រកាសនេះ សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមរយៈការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៃរដ្ឋបាលក្រុង ស្រុក និងការិយាល័យផែនការ និងហិរញ្ញវត្ថុនៃរដ្ឋបាលខណ្ឌ ដាក់ជូនគណៈអភិបាលក្រុង ស្រុក ខណ្ឌ ពិនិត្យនិងសម្រេច រួចបញ្ជូនទៅរតនាគាររាជធានី ខេត្ត ដើម្បីអនុវត្តនីតិវិធីបើកផ្ដល់សាច់ប្រាក់មុន។

**ប្រការ១០.**_

រតនាគាររាជធានី ខេត្ត ត្រូវបង្វែរសាច់ប្រាក់ចូលគណនីធនាគាររបស់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមពេលកំណត់ដូចមានចែងក្នុងប្រការ៨ នៃប្រកាសនេះ ដោយប្រើប្រាស់ប្រព័ន្ធធនាគារ។

រតនាគាររាជធានី ខេត្ត ត្រូវបង្វែរសាច់ប្រាក់ចូលគណនីធនាគាររបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់អនុវត្តមុខងារអប់រំក្រៅប្រព័ន្ធ តាមពេលកំណត់ដូចមានចែងក្នុងប្រការ៨ នៃប្រកាសនេះ ដោយប្រើប្រាស់ប្រព័ន្ធធនាគារ។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុញ្ញាតឱ្យគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ បន្តប្រើប្រាស់គណនីនៅធនាគារដៃគូដែលមានស្រាប់ សម្រាប់កិច្ចប្រតិបត្តិការសាច់ប្រាក់របស់ខ្លួន។ ដោយឡែក គ្រឹះស្ថានសិក្សាសាធារណៈ ដែលត្រូវបានបង្កើតថ្មី និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានតម្រូវការគណនីធនាគារសម្រាប់កិច្ចប្រតិបត្តិការសាច់ប្រាក់របស់ខ្លួន អាចបើកគណនីនៅតាមធនាគារដៃគូណាមួយសមស្រប បន្ទាប់ពីទទួលបានគោលការណ៍អនុញ្ញាតបើកគណនីពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមរយៈក្រសួងអប់រំ យុវជន និងកីឡា។

## ផ្នែកទី២
## ការគ្រប់គ្រងសាច់ប្រាក់

**ប្រការ១១._**

នៅពេលដែលបានទទួលសាច់ប្រាក់ គ្រប់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ត្រូវប្រជុំផ្សព្វផ្សាយ និងបិទផ្សាយលើបញ្ជរព័ត៌មានជូនដល់លោកគ្រូ អ្នកគ្រូ គណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ នូវព័ត៌មានអំពីចំនួនទឹកប្រាក់ដែលបានទទួល និងគម្រោងចំណាយប្រចាំត្រីមាស។

**ប្រការ១២._**

គណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ (គ.ម.ស) របស់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ព្រមទាំងគណៈកម្មការគ្រប់គ្រងសាលារៀន (គ.គ.ស) ត្រូវសហការចាត់ចែង គ្រប់គ្រង និងទទួលខុសត្រូវលើការចំណាយថវិការបស់អង្គភាពខ្លួន ប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។

នាយក ឬប្រធានគណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ត្រូវគ្រប់គ្រង និងទទួលខុសត្រូវលើការចំណាយថវិការបស់អង្គភាពខ្លួន ប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។

ប្រធានការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រង និងទទួលខុសត្រូវលើការចំណាយថវិការបស់អង្គភាពខ្លួន ប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។

## ផ្នែកទី៣
## នីតិវិធីចលនាឥណទានថវិកា

**ប្រការ១៣.-**

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តចំណាយមិនលើសពីទំហំឥណទានថវិកាដែលបានបែងចែកតាមសៀវភៅថវិកាប្រចាំឆ្នាំឡើយ លើកលែងតែមានការបន្ថែមឥណទានថវិកា និងការធ្វើនិយ័តកម្មឥណទានថវិកាដែលត្រូវបានអនុញ្ញាតចាប់ពីដើមត្រីមាសទី២។

**ប្រការ១៤.-**

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើសំណើសុំការអនុម័ត និងមានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ សម្រាប់ការធ្វើនិយ័តកម្មឥណទានថវិកាផ្ទៃក្នុងក្រុង ស្រុក ខណ្ឌតែមួយ ក្នុងជំពូកតែមួយ នៃចង្កោមសកម្មភាពតែមួយ។

**ប្រការ១៥.-**

រដ្ឋបាលក្រុង ស្រុក ត្រូវធ្វើសំណើមកអគ្គនាយកដ្ឋានថវិកា និងចម្លងជូនអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការស្នើសុំបន្ថែមឥណទានថវិកា និងការធ្វើនិយ័តកម្មឥណទានថវិកាក្នុងលក្ខខណ្ឌដែលមិនត្រូវបានធ្វើប្រតិភូកម្មអំណាច។

រដ្ឋបាលខណ្ឌ ត្រូវធ្វើសំណើមកអគ្គនាយកដ្ឋានថវិកា តាមរយៈរដ្ឋបាលរាជធានីភ្នំពេញ និងចម្លងជូនអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការស្នើសុំបន្ថែមឥណទានថវិកា និងការធ្វើនិយ័តកម្មឥណទានថវិកាក្នុងលក្ខខណ្ឌដែលមិនត្រូវបានធ្វើប្រតិភូកម្មអំណាច។

ការធ្វើនិយ័តកម្មឥណទានថវិកាក្នុងលក្ខខណ្ឌដែលមិនត្រូវបានធ្វើប្រតិភូកម្មអំណាច រួមមាន៖

១-ការធ្វើនិយ័តកម្មឥណទានថវិកាផ្ទៃក្នុងក្រុង ស្រុក ខណ្ឌតែមួយ ពីជំពូកមួយ ទៅជំពូកមួយទៀត និង/ឬ ពីចង្កោមសកម្មភាពមួយ ទៅចង្កោមសកម្មភាពមួយទៀត។

២-ការធ្វើនិយ័តកម្មឥណទានថវិកាក្នុងអនុគណនី ៦៤០២៣ (ប្រាក់បំណាច់ម៉ោងបន្ថែម) អនុគណនី ៦៤០២៦ (ប្រាក់បំណាច់តំបន់) និងអនុគណនី ៦៤០៤១ (បៀវត្សមូលដ្ឋាន បុគ្គលិកជាប់កិច្ចសន្យា)។

ការបន្ថែមឥណទានថវិកា និងការធ្វើនិយ័តកម្មឥណទានថវិកាខាងលើ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៤
## ការទូទាត់ និងកិច្ចបញ្ជិកាគណនេយ្យ

**ប្រការ១៦.-**

ហេរញ្ញិករបស់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ត្រូវកាន់បញ្ជីតាមដានសាច់ប្រាក់នៅធនាគារ និងបញ្ជីបេឡា។

ហេរញ្ញិករបស់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ និងមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុនៃការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវប្រមូលឯកសារ លិខិតយុត្តិការ និងសក្ខីបត្រចំណាយរួមមាន៖ លិខិតស្នើសុំថវិកា វិក្កយបត្រ ឬសក្ខីបត្រចំណាយផ្សេងៗ និងបណ្ណចំណាយ ដើម្បីរៀបចំរបាយការណ៍ទូទាត់ចំណាយថវិកាតាមជំពូក គណនី និងអនុគណនី ជូនទៅការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ លិខិតយុត្តិការ និងសក្ខីបត្រច្បាប់ដើមទាំងនោះ ត្រូវរក្សាទុកនៅអង្គភាពដើម សម្រាប់ជាកម្មវត្ថុនៃការធ្វើសវនកម្មក្រោយចំណាយ។

ហេរញ្ញិករបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ត្រូវប្រមូលឯកសារ លិខិតយុត្តិការ និងសក្ខីបត្រចំណាយ ដើម្បីរៀបចំរបាយការណ៍ចំណាយជូនទៅការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវប្រមូលរបាយការណ៍ទូទាត់ចំណាយថវិកាពីគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត មណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ នៅតាមក្រុង ស្រុក ខណ្ឌ និងចំណាយគាំទ្រផ្នែករដ្ឋបាលរបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីរៀបចំបូកសរុបជាតារាងរបាយការណ៍ទូទាត់ចំណាយថវិកាតាមជំពូក គណនី អនុគណនី ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន រួចជូនទៅការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៃរដ្ឋបាលក្រុង ស្រុក និងការិយាល័យផែនការ និងហិរញ្ញវត្ថុនៃរដ្ឋបាលខណ្ឌ។ ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៃរដ្ឋបាលក្រុង ស្រុក ត្រូវរៀបចំបោះផ្សាយអាណត្តិនិយ័តកម្ម ដាក់ជូនអភិបាលនៃគណៈអភិបាលក្រុង ស្រុក ចុះហត្ថលេខា រួចបញ្ជូនទៅរតនាគារខេត្ត ដើម្បីពិនិត្យ និងទូទាត់ជម្រះបញ្ជី។ ការិយាល័យផែនការ និងហិរញ្ញវត្ថុ នៃរដ្ឋបាលខណ្ឌ ត្រូវរៀបចំបោះផ្សាយអាណត្តិនិយ័តកម្ម ដាក់ជូនអភិបាលនៃគណៈអភិបាលខណ្ឌចុះហត្ថលេខា រួចបញ្ជូនទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ដើម្បីត្រួតពិនិត្យថវិកា និងបញ្ជូនទៅរតនាគាររាជធានី ដើម្បីទូទាត់ជម្រះបញ្ជី។ ឯកសារដែលត្រូវភ្ជាប់ជាមួយ មានដូចខាងក្រោម៖

- លិខិតស្នើសុំទូទាត់ថវិកា
- សាលាកបត្រកត់ត្រាចំណាយនិងត្រួតពិនិត្យហិរញ្ញវត្ថុ
- ដីកាអមលិខិតយុត្តិការ
- ដីកាអមបញ្ចេញអាណត្តិនិយ័តកម្ម
- អាណត្តិនិយ័តកម្ម
- និងរបាយការណ៍ទូទាត់ចំណាយថវិកា (ជំពូក គណនី អនុគណនី) ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ១៧._**

គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ និង

ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ មិនត្រូវបានអនុញ្ញាតឱ្យរក្សាទុកសាច់ប្រាក់នៅសល់ចុងឆ្នាំសម្រាប់ចំណាយនៅឆ្នាំបន្ទាប់ឡើយ។ ក្នុងករណីមានសាច់ប្រាក់នៅសល់ចុងឆ្នាំ គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបង់ប្រាក់ចូលគណនីធនាគាររបស់រតនាគាររាជធានី ខេត្តវិញ យ៉ាងយូរត្រឹមថ្ងៃទី២៥ ខែធ្នូ នៃឆ្នាំនីមួយៗ ហើយផ្អែកតាមប្រកាសពីធនាគារដែលទទួលបាន ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបូកសរុប និងបញ្ជូនទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីរៀបចំសំណើបង់សាច់ប្រាក់សល់ពីការបើកផ្តល់មុន ទៅរតនាគាររាជធានី ខេត្ត។

**ប្រការ១៨._**

គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ និងការិយាល័យ អប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវកត់ត្រាចំណូល ចំណាយ ក្នុងបញ្ជីមួយចំនួនដូចខាងក្រោម៖

- បញ្ជីតាមដានសាច់ប្រាក់នៅធនាគារ (កត់ត្រាដោយយោងតាមរបាយការណ៍របស់ធនាគារ ឬបណ្ណបង់ប្រាក់ បណ្ណដកប្រាក់ ឬ ប្រកាសឥណពន្ធ ប្រកាសឥណទាន)
- បញ្ជីបេឡា (កត់ត្រាដោយយោងតាមបណ្ណចំណូល បណ្ណចំណាយ)
- បញ្ជីសម្ភារៈ (បណ្ណបញ្ចូលសម្ភារៈទំនិញ បណ្ណបញ្ចេញសម្ភារៈទំនិញ និងបញ្ជីវិភាគសម្ភារៈទំនិញ)។

**ប្រការ១៩._**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងចេញសារាចរស្តីពីកិច្ចបញ្ជិកាគណនេយ្យ លើការអនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ និងការគាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយពិគ្រោះយោបល់ជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងមហាផ្ទៃ។

## ផ្នែកទី៥
## ការរៀបចំរបាយការណ៍

**ប្រការ២០._**

គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំរបាយការណ៍ចំណាយថវិកា និងរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ តាមយន្តការ បែបបទ និងនីតិវិធីជាធរមាន។

ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបូកសរុបរបាយការណ៍ចំណាយថវិកា និងរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ តាមទម្រង់របាយការណ៍ដែលបានកំណត់ និងបញ្ជូនមកការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៃរដ្ឋបាលក្រុង ស្រុក និងការិយាល័យផែនការ និងហិរញ្ញវត្ថុនៃរដ្ឋបាលខណ្ឌ ដើម្បីដាក់ជូនគណៈអភិបាលក្រុង ស្រុក ខណ្ឌ ពិនិត្យ និងសម្រេច។ របាយការណ៍ចំណាយថវិកា និងរបាយការណ៍សមិទ្ធកម្មនេះ ត្រូវផ្ញើជូនរដ្ឋបាលរាជធានី ខេត្ត ចំនួន ១ (មួយ) ច្បាប់ និងជូនមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចំនួន ១ (មួយ) ច្បាប់ ដើម្បីបូកសរុប និងផ្ញើជូនក្រសួងអប់រំ យុវជន និងកីឡា ឱ្យទាន់ពេលវេលាកំណត់។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ចូលរបាយការណ៍វឌ្ឍនភាពប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំនៃការអនុវត្តមុខងារអប់រំ យុវជន និងកីឡា ទៅក្នុងរបាយការណ៍វឌ្ឍនភាពប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមទម្រង់ បែបបទ និងនីតិវិធីកំណត់។

**ប្រការ២១._**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំស្ដីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ ដោយពិគ្រោះយោបល់ជាមួយនឹងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**ប្រការ២២._**

កញ្ចប់ថវិការបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់គាំទ្រផ្នែករដ្ឋបាលក្នុងការអនុវត្តមុខងារអប់រំ យុវជន និងកីឡា ដែលបានប្រគល់ និងបានធ្វើប្រតិភូកម្មនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមនីតិវិធីនៃប្រកាសនេះ ចាប់ពីឆ្នាំថវិកា២០២៥ តទៅ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ២៣._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២៤.-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ព្រមទាំងគ្រប់ក្រុមប្រឹក្សា និងអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ប្រធានការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងអង្គភាពក្រោមឱវាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ... ខែ ... ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ ... ឆ្នាំ២០២៤

| ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី<br>ក្រសួងអប់រំ យុវជន និងកីឡា | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី<br>ក្រសួងមហាផ្ទៃ |
|---|---|---|
| អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន | បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន | អភិសន្តិបណ្ឌិត ស សុខា |

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋាន គ.ជ.អ.ប
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ២៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ